តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

សង្ខេបគោលនយោបាយ

# សារៈសំខាន់ នៃច្បាប់ការពារសាក្សី និងអ្នករាយការណ៍






អ្នកនិពន្ធ៖ បណ្ឌិត Renata Suter
តម្លាភាពកម្ពុជា
ខែមករា ២០១៦

អ្នករាយការណ៍ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ដើម្បីលើកទឹកចិត្តពួកគេនៅក្នុងការបញ្ចេញព័ត៌មាន ការការពារផ្លូវច្បាប់គឺពិតជាមានសារៈសំខាន់ណាស់ ដូចដែលមានបរិយាយនៅក្នុងយុទ្ធសាស្ត្រអនុវត្តច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ នៃយុទ្ធសាស្ត្រចតុកោណសម្រាប់ការអភិវឌ្ឍ និងដូចដែលមានចែងនៅក្នុងមាត្រា ១៣ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន អាចមានផលប៉ះពាល់មិនល្អដល់ការរាយការណ៍ ដោយហេតុថាការកាពារដោយសមស្របចំពោះអ្នករាយការណ៍ដោយស្មោះត្រង់មិនត្រូវបានធានា ហើយថែមទាំងមានការគម្រាមកំហែងដាក់ពន្ធនាគារទៀតផង (មាត្រា ៤១)។ ដើម្បីលើកកម្ពស់ការរាយការណ៍ព័ត៌មានអំពីអំពើពុករលួយ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអំពីការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការការពារសាក្សី និងអ្នករាយការណ៍។ ដោយសាររាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ច្បាប់ដែលនឹងត្រូវតាក់តែងនេះ គួរតែអនុលោមទៅតាមមាត្រា ៣៣ ស្ដីពីការការពារបុគ្គលដែលបញ្ចេញព័ត៌មានអំពីអំពើពុករលួយ។ ជាពិសេសច្បាប់ថ្មីនេះ គួរគប្បីការពារដល់បុគ្គលគ្រប់រូបដែលរាយការណ៍អំពើពុករលួយ ក្នុងគោលបំណងស្មោះត្រង់ និងមានមូលដ្ឋានសមហេតុផល ពីការធ្វើទុក្ខបុកម្នេញដោយអយុត្តិធម៌ណាមួយ។

សេចក្ដីសង្ខេបគោលនយោបាយនេះ ទីមួយ នឹងបង្ហាញថាតើច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយបច្ចុប្បន្ន គួរតែត្រូវបានធ្វើវិសោធនកម្មដូចម្ដេចដើម្បីការពារសាក្សី និងអ្នករាយការណ៍ និងលើកទឹកចិត្តពួកគេនៅក្នុងការរាយការណ៍? ទីពីរ សេចក្ដីសង្ខេបនេះ លើកឡើងគ្រួសៗនូវបទពិសោធន៍អនុវត្តល្អៗ[1] ពីប្រទេសដទៃក្នុងលោក ដែលអាចផ្ដល់ជាគំរូ សម្រាប់ការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការការពារសាក្សី និងអ្នករាយការណ៍នៅប្រទេសកម្ពុជាយើង។

## អំពើពុករលួយ និងសារៈសំខាន់នៃអ្នករាយការណ៍

អំពើពុករលួយ ជាបញ្ហាសង្គម នយោបាយ និងសេដ្ឋកិច្ចដ៏ចាក់ស្រេះ ដែលប៉ះពាល់គ្រប់ប្រទេស និងគ្រប់វិស័យទាំងអស់នៃជីវិតសាធារណៈ។ អំពើពុករលួយត្រូវបានឲ្យនិយមន័យថាជាការប្រើប្រាស់ដោយមិនត្រឹមត្រូវ នូវអំណាចដែលផ្ដល់ឲ្យដើម្បីស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួន[2]។ អំពើពុករលួយ ពន្យឺតការអភិវឌ្ឍសេដ្ឋកិច្ច ធ្វើឲ្យខូចស្ថាប័នប្រជាធិបតេយ្យ គម្រាមកំហែងដល់ស្ថិរភាពសង្គម និងនយោបាយ ព្រមទាំងជាមូលហេតុចម្បងនាំឲ្យមានភាពក្រីក្រ។

គន្លឹះនៅក្នុងការទប់ស្កាត់អំពើពុករលួយ គឺយន្តការដ៏មានប្រសិទ្ធភាព ដែលលើកទឹកចិត្តដល់ប្រជាជនក្នុងការផ្ដល់ព័ត៌មានអំពីអំពើពុករលួយ និងសកម្មភាពខុសច្បាប់ផ្សេងទៀត ព្រមទាំងការពារពួកគេនៅពេលដែលគេរាយការណ៍។ ពាក្យ "អ្នករាយការណ៍" សំដៅទៅលើបុគ្គលដែលលាតត្រដាងនូវព័ត៌មាន ឬសកម្មភាពដែលត្រូវបានចាត់ទុកថាជាអំពើពុករលួយ ឬមិនស្របច្បាប់ ជាលក្ខណៈសាធាណៈ ឬឯកជនក្ដី ហើយដែលរឿងនោះគម្រាមកំហែងដល់ផលប្រយោជន៍សាធារណៈ[3]។ ដោយសារពួកគេនៅកៀកប្រភពបញ្ហា ដូចជានិយោជិតដែលធ្វើការនៅក្នុងស្ថាប័នជាក់លាក់ណាមួយជាដើម អ្នករាយការណ៍ ច្រើនតែដឹងអំពីទង្វើមិនត្រឹមត្រូវ ដែលទង្វើនោះបើគ្មានអ្នកទាំងនោះលាតត្រដាងទេ នឹងគ្មាននរណាដឹងទាំងអស់។

នៅសហរដ្ឋអាមេរិក ច្បាប់ស្ដីពីការគែបន្លំ ដែលអនុញ្ញាតឲ្យបុគ្គលឯកជនប្ដឹងជនណាដែលប្រព្រឹត្តបទល្មើសគែបន្លំពីកម្មវិធីនយោបាយរបស់រដ្ឋាភិបាល បានប្រមូលថវិកាមកវិញចំនួន ៥៥ ពាន់លានដុល្លា ទៅឲ្យរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋនានាចាប់តាំងពីមានការធ្វើវិសោធនកម្ម ដើម្បីពង្រឹងច្បាប់ស្ដីពីការគែបន្លំនេះនៅឆ្នាំ ១៩៨៧ មក[4]។ ក្នុងឆ្នាំ ២០១២ ក្រសួងយុត្តិធម៌របស់សហរដ្ឋអាមេរិច បានប្រមូលមកវិញនូវទឹកប្រាក់ចំនួន ៤,៩ ពាន់លានដុល្លា ក្នុងសំណុំរឿងគែបន្លំប្រាក់រដ្ឋាភិបាល។ លើសពីពាក់កណ្ដាលនៃទឹកលុយដែលប្រមូលបានមកវិញ (៣.៣ ពាន់លានដុល្លា) គឺធ្វើឡើងតាមរយៈព័ត៌មាន ដែលផ្ដល់ដោយអ្នករាយការណ៍ព័ត៌មាន[5]។ លើសពីនេះ ការស្រាវជ្រាវមួយ ដែលបានធ្វើឡើងដើម្បីកំណត់យន្តការមានប្រសិទ្ធភាពបំផុតសម្រាប់ស៊ើបអង្កេតករណី

1 Transparency International, International principles for whistleblower legislation: Best practices for laws to protect whistleblowers and support whistleblowing in the public interest, 2013

2 Transparency International, organization website, FAQs on Corruption: http://www.transparency.org/whoweare/organisation/faqs_on_corruption [accessed 21 May 2015]

3 is Vandekerckhove, W. (2006). Whistleblowing and Organizational Social Responsibility: A Global Assessment. Ashgate

4 Fraud Statistics Overview, Civil Division, U.S. Department of Justice http://www.taf.org/resource/fca/statistics as well as http://www.taf.org/resource/fca/faq#faq6

5 The United States Department of Justice, Justince News, December 4, 2012. Available at: http://www.justice.gov/opa/pr/justice-department-recovers-nearly-5-billion-false-claims-act-cases-fiscal-year-2012

គៃបន្លំនៅក្នុងក្រុមហ៊ុន បានសិក្សាបទល្មើសគៃបន្លំចំនួន ២១៦ករណី នៅក្នុងបណ្តាក្រុមហ៊ុនធំៗរបស់សហរដ្ឋអាមេរិក ចន្លោះឆ្នាំ១៩៩៦-២០០៤។ ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ការរកឃើញបទល្មើសគៃបន្លំ ពឹងផ្អែកជាចម្បងលើពត៌មានដែលផ្តល់ឲ្យដោយនិយោជិត សារព័ត៌មាន និងនិយ័តករសហគ្រាស ជាជាងព័ត៌មានដែលផ្តល់ឲ្យដោយអ្នកមានសមត្ថកិច្ចដូចជា សវនករជាដើម[6]។ លទ្ធផលស្រដៀងគ្នានេះបានមកពីការសិក្សារបស់ ខេភីអេមជី (KPMG) ដែលក្នុងនោះការសិក្សាធ្វើឡើងនៅប្រទេសអូស្រ្តាលី និងប្រទេសញូហ្ស៊ីឡេនក្នុងឆ្នាំ ២០១២ បានរកឃើញថា ២៥% នៃបទល្មើសគៃបន្លំដែលត្រូវចាប់បាន ត្រូវបានផ្តល់ព័ត៌មានដោយនិយោជិត[7] ។ ទិន្នន័យផ្សេងទៀតបានមកពីការសិក្សាដែលធ្វើឡើងនៅទ្វីបអាហ្វ្រិក ក្នុងឆ្នាំ ២០០៥ បានរកឃើញថា ៤៤% នៃករណីគៃបន្លំ ត្រូវបានលាតត្រដាងដោយអ្នករាយការណ៍[8]។ ទិន្នន័យទាំងនេះបង្ហាញឲ្យឃើញថា ការចូលរួមរបស់អ្នករាយការណ៍ជួយការពារហិរញ្ញវត្ថុ លើកស្ទួយនីតិរដ្ឋ ហើយនៅក្នុងករណីផ្សេងៗទៀតជួយសង្គ្រោះជីវិត និងការពារសិទ្ធិមនុស្ស ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការលាតត្រដាងព័ត៌មានសាធារណៈសំខាន់ៗដើម្បីការពារផលប្រយោជន៍សាធារណៈ សាក្សី និងអ្នករាយការណ៍ ជារឿយៗត្រូវប្រឈមមុខនឹងហានិភ័យខ្ពស់។ ពួកគេអាចនឹងក្លាយជាកម្មវត្ថុនៃការបំភិតបំភ័យ ការរុកកួន ការបណ្តេញចេញឬអំពើហិង្សាព្រមទាំងប្រឈមនឹងគ្រោះថ្នាក់ក្នុងជីវិតប្រចាំថ្ងៃ ការប៉ះពាល់កិត្តិយស និងករណីធ្ងន់ធ្ងរទៀតគឺគ្រោះថ្នាក់រហូតដល់អាយុជីវិតរបស់ពួកគេ និងសមាជិកគ្រួសាររបស់ពួកគេទៀតផង។ ហេតុដូច្នេះ ការលើកទឹកចិត្តឲ្យមានការរាយការណ៍អំពើពុករលួយ ត្រូវតែរួមផ្សំជាមួយនឹងការការពារផ្លូវច្បាប់ និងការណែនាំដោយច្បាស់លាស់អំពីនីតិវិធីនៃការរាយការណ៍។

## ■ ស្ថានភាពច្បាប់នៅកម្ពុជា

អំពើពុករលួយ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយនៅកម្ពុជា។ របាយការណ៍ និងសូចនាករអន្តរជាតិនានា តែងតែបង្ហាញជាបន្តបន្ទាប់ អំពីអំពើពុករលួយនៅក្នុងកម្រិតដ៏ខ្ពស់[9]។ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញពីការប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងអំពើពុករលួយម្តងហើយម្តងទៀត ។ រាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយនៅឆ្នាំ ២០០៧[10]។ រាជរដ្ឋាភិបាលបានក៏បានផ្តល់អាទិភាពទៅលើការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងយុទ្ធសាស្រ្តចតុកោណសម្រាប់ការអភិវឌ្ឍ[11] ព្រមទាំងបានអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៅឆ្នាំ ២០១០[12] ។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនេះបានបង្កើតឲ្យមាននូវស្ថាប័នប្រឆាំងអំពើពុករលួយរួមមាន អង្គភាពប្រឆាំងអំពើពុករលួយ និងក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយមានភារកិច្ចអនុវត្តច្បាប់ពាក់ព័ន្ធនឹងអំពើពុករលួយ និងដឹកនាំការងារទប់ស្កាត់អំពើពុករលួយ[13] ។ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយជាក្រុមប្រឹក្សាភិបាលរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលមានភារកិច្ចពិគ្រោះយោបល់ និង ផ្តល់អនុសាសន៍លើការកសាងយុទ្ធសាស្រ្ត និងគោលនយោបាយប្រឆាំងអំពើពុករលួយ។ ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយមានសមាជិក ១១រូប ដែលមានសមាសភាពមកពីបណ្តាស្ថាប័នរាជរដ្ឋាភិបាល[14]។ លើសពីនេះ បន្ទាប់ពីមានការបោះឆ្នោតនៅឆ្នាំ ២០១៣ រដ្ឋសភាបានបង្កើតនូវគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ (គណៈកម្មការទី១០)។ ទំនួលខុសត្រូវចម្បងរបស់គណៈកម្មការនេះគឺធ្វើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីស្នើច្បាប់ពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ ព្រមទាំងតាមដានការអនុវត្តច្បាប់ទាំងនោះដោយស្ថាប័នពាក់ព័ន្ធ[15] ។

## ■ តើធ្វើដូចម្តេចដើម្បីលើកទឹកចិត្តបុគ្គលគ្រប់រូបឲ្យរាយការណ៍អំពើពុករលួយ ? ?

រាជរដ្ឋាភិបាលកម្ពុជា អាចទទួលបាននូវផលប្រយោជន៍ពីព័ត៌មានដែលផ្តល់ឲ្យដោយអ្នករាយការណ៍។ ទោះជា

6 Dyck, I. J. A., Morse, A., & Zingales, L. (2009). Who blows the whistle on corporate fraud? http://papers.ssrn.com/sol3/papers.cfm?abstract_id=891482
7 Cited in Scholtens, Review of the Operation of the Protected Disclosures Act - Report to the Minister of State Services (NZ), December 2003 at 3.31. (NZ Review)
8 KPMG Forensic Africa, Africa Fraud and Misconduct Survey 2005.
9 Transparency International, Global Corruption Barometer, 2013 (Berlin: Transparency International, 2013); Transparency International, Corruption Perception Index 2014
10 United Nations Office on Drug and Crime, Convention Against Corruption: Signatories and Ratification Status, Updated 15 April 2015 http://www.unodc.org/unodc/en/treaties/CAC/signatories.html [accessed 20 Mai 2015]
11 Samdech Techo Hun Sen, Prime Minister. Rectangular Strategy for Growth Phase III (Phnom Penh: Royal Government of Cambodia, 2013)
12 Law on Anti-Corruption, 2010
13 Law on Anti-Corruption, 2010: Art. 25
14 Law on Anti-Corruption, 2010: Art. 6
15 Decision on Roles and Responsibilities of Commission on Investigation and Anti-Corruption of the National Assembly, the National Assembly of Cambodia, 2014

យ៉ាងណា ថ្វីបើមានការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយយ៉ាងណាក៏ដោយ ក៏ប្រជាជនកម្ពុជាជាច្រើនដែលដឹងអំពីអំពើពុករលួយមិនធ្វើការរាយការណ៍នោះទេ។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ ២០១៤ អង្គភាពប្រឆាំងអំពើពុករលួយបានទទួលពាក្យបណ្ដឹងចំនួន ៨៩៩ ករណី[16] ដែលតួលេខនេះជាចំនួនទាបនៅឡើយ បើប្រៀបធៀបទៅនឹងការដែលកម្ពុជាត្រូវបានចាត់ចំណាត់ថ្នាក់ ម្ដងហើយម្ដងទៀតថាជាប្រទេសមួយមានអំពើពុករលួយខ្ពស់[17]។ ការសិក្សាទូទាំងប្រទេសមួយកាលពីពេលថ្មីៗនេះបានបង្ហាញថា ឧបសគ្គរាំងប្រជាពលរដ្ឋនៅក្នុងការរាយការណ៍អំពើពុករលួយរួមមាន ការភ័យខ្លាចការមិនត្រូវទទួលបានការការពារ និងកង្វះចំណេះដឹងអំពីនីតិវិធីក្នុងការរាយការណ៍ (ប្រអប់១)[18]។

## ប្រអប់ទី ១

### ឧបសគ្គរារាំងយុវជនកម្ពុជាពីការរាយការណ៍អំពើពុករលួយ

ការសិក្សាថ្នាក់ជាតិនៅឆ្នាំ២០១៥ ដែលបានធ្វើឡើងក្នុងចំណោមយុវជនកម្ពុជា ១២០០ នាក់ អាយុចន្លោះពី ១៥ ទៅ ៣០ឆ្នាំ បានបង្ហាញថា បើទោះជា៦៧%នៃយុវជនបាននិយាយថាជាគោលការណ៍ ពួកគេមានឆន្ទៈក្នុងការរាយការណ៍អំពើពុករលួយប្រសិនបើពួកគេជួបប្រទះនូវអំពើពុករលួយក្ដី មានតែ ៨% ប៉ុណ្ណោះដែលបានបញ្ជាក់ថាពួកគេពិតជាធ្លាប់បានរាយការណ៍ បើទោះបីជាអ្នកដែលត្រូវបានសាកសួរទាំងនោះ ភាគច្រើនមានបទពិសោធន៍ជួបប្រទះនឹងអំពើពុករលួយក៏ដោយ។ មួយភាគបី (៣៣%) នៃអ្នកដែលត្រូវបានស្ទង់មតិបានបង្ហាញថា ពួកគេមានការស្ទាក់ស្ទើរនៅក្នុងការរាយការណ៍ពីអំពើពុករលួយ។ ការភ័យខ្លាចការមិនត្រូវបានការពារ ការយល់ឃើញថាការរាយការណ៍នឹងមិនមានប្រសិទ្ធភាព និងកង្វះខាតចំណេះដឹងអំពីនីតិវិធីនៃការផ្ដល់ព័ត៌មានគឺជាឧបសគ្គចម្បងដែលរាំងយុវជនពីការរាយការណ៍អំពើពុករលួយ។

(ប្រភពៈ Transparency International Cambodia, Questioning Corruption: A National Survey on Youth Perceptions of Corruption and Integrity in Cambodia. 2015)

ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយឲ្យមានប្រសិទ្ធភាព ជាការចាំបាច់ណាស់ដែលត្រូវយកចេញនូវរាល់ឧបសគ្គដែលរារាំងបុគ្គលនានាពីការរាយការណ៍។ ម្យ៉ាង បញ្ញត្តិមួយចំនួននៅក្នុងច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយបច្ចុប្បន្ននេះ គួរតែត្រូវបានកែលម្អឡើងវិញ ដោយសារតែវាមិនបានផ្ដល់នូវការការពារដ៏សមស្របដល់អ្នករាយការណ៍ដែលធ្វើឡើងក្នុងគោលបំណងស្មោះត្រង់ ហើយថែមទាំងគម្រាមកំហែងពួកគេដាក់ពន្ធនាគារ បើសិនជាពួកគេមិនអាចផ្ដល់នូវភស្ដុតាងគ្រប់គ្រាន់ដើម្បីគាំទ្រនូវអំណះអំណាងរបស់ខ្លួន។ ស្ថានភាពច្បាប់នាពេលបច្ចុប្បន្ននេះ អាចបន្ថយទឹកចិត្តប្រជាពលរដ្ឋនៅក្នុងការរាយការណ៍ពីអំពើពុករលួយ។ ម្យ៉ាងវិញទៀត ច្បាប់ថ្មីមួយដែលអនុលោមតាមអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ អាចការពារ និងធានានូវសុវត្ថិភាពដល់បុគ្គលគ្រប់រូប ដែលបញ្ចេញព័ត៌មាន។ ហើយវាអាចក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយ ក្នុងការលើកទឹកចិត្តទៅដល់ការផ្ដល់ព័ត៌មានការស៊ើបអង្កេត និងការប្រឆាំងអំពើពុករលួយ។

## ភាពចាំបាច់នៃវិសោធនកម្មច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ

ដើម្បីពង្រឹងច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ហើយដើម្បីធានាថាច្បាប់នេះអនុលោមទៅតាមមាត្រា ៣៣ ស្ដីពីការការពារអ្នករាយការណ៍នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ (ប្រអប់២) យើងសូមបង្ហាញជូននូវគំនិតមួយចំនួន

## ប្រអប់ទី ២

### មាត្រា ៣៣ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្ដីការការពារសាក្សី និងអ្នករាយការណ៍

រដ្ឋជាសមាជិក ត្រូវពិចារណាដាក់បញ្ចូលនូវវិធានការសមស្របទៅក្នុងប្រព័ន្ធច្បាប់របស់ខ្លួន ដើម្បីផ្ដល់នូវការការពារប្រឆាំងទៅនឹងអំពើអយុត្តិធម៌ដែលធ្វើឡើងចំពោះបុគ្គលដែលរាយការណ៍ដោយបំណងល្អ និងមានមូលដ្ឋានសមហេតុផល ទៅដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតនូវរាល់អង្គហេតុដែលជាបទល្មើស ដូចដែលមានចែងនៅក្នុងអនុសញ្ញានេះ។

(ប្រភពៈ United Nations Convention against Corruption )

16 Anti-Corruption Unit (ACU). http://www.acu.gov.kh
17 Transparency International, Global Corruption Barometer, 2013 (Berlin: Transparency International, 2013); Transparency International, Corruption Perception Index 2014
18 Transparency International Cambodia, Questioning Corruption: A National Survey on Youth Perceptions of Corruption and Integrity in Cambodia (2015)

សម្រាប់ការធ្វើវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនេះ[19]៖

**ទីមួយៈ** មាត្រា ១៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលចែងពីភារកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដូចជា «ត្រូវចាត់វិធានការចាំបាច់ដើម្បីរក្សាសន្តិសុខដល់បុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ»[20]។ ទោះជាយ៉ាងណា ការផ្តល់ព័ត៌មានដោយមានការការពារ និងបុគ្គលដែលទទួលបានការការពារ មិនត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់នោះទេ ដោយចំណុចនេះ គួរតែមានកំណត់ដោយជាក់លាក់មួយ។

**ទីពីរៈ** មាត្រា ៤១ ស្តីពីបទប្តឹងបរិហារដោយភូតកុហក អ្នកប្តឹងត្រូវទទួលទោសពន្ធនាគារពី ១ខែ ទៅ៦ខែ និងពិន័យជាប្រាក់ពី ១សែន ទៅ ១០លានរៀល ប្រសិនបើពាក្យបណ្តឹងដែលប្តឹងទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយត្រូវបានចាត់ទុកថាជា« ព័ត៌មានគ្មានប្រយោជន៍» មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រនូវពាក្យបណ្តឹង[21]។ មាត្រា ៤១ នេះគួរតែត្រូវលុបចោល។ រាល់ការស៊ើបអង្កេតពាក់ព័ន្ធនឹងការចោទប្រកាន់នោះ គួរតែត្រូវបានធ្វើឡើងដោយអនុលោមតាមបញ្ញត្តិស្តីពីបទបរិហារកេរ្តិ៍ជាសាធារណៈ នៅក្នុងក្រមព្រហ្មទណ្ឌ( ឆ្នាំ ២០០៩ មាត្រា ៣០៥ )[22] ដែលច្បាប់នេះមិនអនុញ្ញាតឲ្យមានការឃុំឃាំងជនជាប់ចោទពីបទបរិហាកេរ្តិ៍ដែលធ្វើឡើងដោយបានសម្រេចនោះទេ។ លើសពីនេះទៅទៀត បន្ទុកនៃភស្តុតាងគួរតែប្រគល់ទៅឲ្យអង្គភាពដែលទទួលខុសត្រូវក្នុងរឿងបណ្តឹងនេះ ក្នុងការផ្តល់នូវភស្តុតាង ដែលថាអ្នកបញ្ចេញព័ត៌មានបានៈ

- ប្តឹងខុសចំពោះជនណាម្នាក់ដោយមិនមានភស្តុតាងអំពីសកម្មភាពពុករលួយរបស់ជននោះទេ ហើយ
- បានដឹងពីភាពមិនត្រឹមត្រូវនៃការប្តឹងនោះ។

## រាជរដ្ឋាភិបាលបានប្រកាសការប្តេជ្ញាចិត្តធ្វើសេចក្តីព្រាងច្បាប់ស្តីពីការការពារសាក្សី និងអ្នករាយការណ៍

រាជរដ្ឋាភិបាលកម្ពុជាបានរកឃើញចំណុចដែលអាចកែលម្អបាន នៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលមានជាធរមាន។ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១៤ អង្គភាពប្រឆាំងអំពើពុករលួយ និងគណៈកម្មការទី ១០នៃរដ្ឋសភា បានបង្ហាញពីការប្តេជ្ញាចិត្តរួមគ្នាថា សេចក្តីព្រាងច្បាប់ស្តីពីការការពារសាក្សី និងអ្នករាយការណ៍អំពើពុករលួយ នឹងត្រូវធ្វើឡើងឆាប់ៗនេះ ដើម្បីធានាសុវត្ថិភាពដល់បុគ្គលដែលចង់លាតត្រដាងអំពើពុករលួយ។ ដោយមានគោលដៅអនុវត្តច្បាប់ការពារអ្នករាយការណ៍ រាជរដ្ឋាភិបាលកម្ពុជាបានកំពុងធ្វើដូចបណ្តាប្រទេសមួយចំនួនក្នុងតំបន់អាស៊ីដែលបានអនុម័តច្បាប់ស្តីពីការការពារអ្នកផ្តល់ព័ត៌មានអំពីអំពើពុករលួយក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះរួមមាន ប្រទេសបង់ក្លាដេស ឥណ្ឌា ជប៉ុន ម៉ាឡេស៊ី សាធារណរដ្ឋកូរ៉េ និងវៀតណាម។

បន្ទាប់ពីអនុវត្តច្បាប់នេះ ប្រទេសមួយចំនួនទាំងនោះបានបង្ហាញនូវជោគជ័យដ៏គួរឲ្យកត់សម្គាល់នៅក្នុងការប្រឆាំងអំពើពុករលួយ។ ជាឧទាហរណ៍ សាធារណរដ្ឋកូរ៉េបានអនុម័តច្បាប់មួយដែលមានវិសាលភាពទូលំទូលាយ ដោយមិនត្រឹមតែគ្របដណ្តប់តែទៅលើសកម្មភាពមិនស្របច្បាប់នៅក្នុងវិស័យឯកជន និងវិស័យសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែក៏គ្របដណ្តប់លើគ្រប់បុគ្គលដែលបានដឹងពីសកម្មភាពនៃអំពើពុករលួយផងដែរ។ ចាប់តាំងពីឆ្នាំ ២០០២ ដល់ ២០១២ គណៈកម្មការប្រឆាំងអំពើពុករលួយ និងសិទ្ធិពលរដ្ឋ បានទទួលបណ្តឹងសរុប ២៤,៦២៩ ពីអ្នកបញ្ចេញព័ត៌មាន។ តាមរយៈការចាត់វិធានការតាមបណ្តឹងទាំងនោះ គណៈកម្មការបានប្រមូលមកវិញនូវប្រាក់ប្រមាណ ៥០ លានដុល្លានៅក្នុងរឿងក្តីចំនួន ១៨៣ ករណី។ គ្រាន់តែនៅក្នុងឆ្នាំ ២០១២ ទឹកប្រាក់ប្រមាណ១០ លានដុល្លាត្រូវបានប្រមូលចូលរដ្ឋវិញនៅក្នុង ៤០ ករណី[23] ។ តួលេខនេះបានបង្ហាញថា ការលើកទឹកចិត្តឲ្យប្រជាពលរដ្ឋរាយការណ៍នូវសកម្មភាពមិនស្របច្បាប់ នឹងការពារពួកគេនៅពេលដែលពួកគេផ្តល់ព័ត៌មាន តាមរយៈច្បាប់ដ៏ទូលំទូលាយមួយ គឺជាមធ្យោបាយដ៏ជោគជ័យមួយ ដើម្បីបញ្ចៀស

19 Transparency International Cambodia, Corruption and Cambodia's Governance System (2014): 'Anti-Corruption Institution (ACI)' pillar report; Transparency International, International principles for whistleblower legislation: Best practices for laws to protect whistleblowers and support whistleblowing in the public interest, 2013; United Nations Office on Drug and Crime, United Nations Convention Against Corruption. United Nations, New York, 2004

20 Law on Anti-Corruption, 2010, Article 13; see also Samdech Techo Hun Sen, Prime Minister. Rectangular Strategy for Growth Phase III (Phnom Penh: Royal Government of Cambodia, 2013)

21 Law on Anti-Corruption, 2010, Article 41

22 Penal Code (2009, Art. 305)

23 Anti-Corruption and Civil Rights Commission, Korea Transparency Newsletter (Spring 2013), available at: http://www.acrc.go.kr/eng/board.do?command=searchDetail&method=searchDetailViewInc&menuId=020503&confId=63&conConfId=63&conTabId=0&currPageNo=1&boardNum=35638

នូវការបាត់បង់នូវទឹកប្រាក់របស់ក្រុមហ៊ុន និងរដ្ឋ ដ៏ច្រើនសន្ធឹកសន្ធាប់ទៅលើអំពើពុករលួយ។

## អនុសាសន៍សម្រាប់ច្បាប់ថ្មីស្តីពីការការពារអ្នកបញ្ចេញព័ត៌មាន និងសាក្សី

ដើម្បីធានាថា ច្បាប់ថ្មីមួយស្តីពីការការពារសាក្សី និងអ្នករាយការណ៍ អនុលោមទៅតាមមាត្រា ៣៣ នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ វាតម្រូវឲ្យមានការធានាថា បុគ្គលដែលរាយការណ៍អំពីអំពើពុករលួយដោយបំណងស្មោះត្រង់ត្រូវទទួលបានការការពារ ទទួលបានការធានាជំនួយផ្នែកច្បាប់ ហើយមិនត្រូវជាប់ពន្ធនាគារឡើយ។ដើម្បីអនុវត្តមុខងារនេះអង្គភាពប្រឆាំងអំពើពុករលួយត្រូវមានធនធាន និងសមត្ថភាពគ្រប់គ្រាន់។

អង្គការតម្លាភាពអន្តរជាតិ ទើបតែបានបោះពុម្ពផ្សាយនូវគោលការណ៍អន្តរជាតិសម្រាប់ច្បាប់ស្តីពីការការពារសាក្សី និងអ្នករាយការណ៍[24]។ អង្គការតម្លាភាពកម្ពុជាយល់ថា ការធ្វើសេចក្តីព្រាងច្បាប់ការពារអ្នកផ្តល់ព័ត៌មានអំពើពុករលួយរបស់កម្ពុជាគួរផ្អែកលើគោលការណ៍ទាំងនោះ។ ជាពិសេសជាការល្អ ក្នុងការការផ្តោតការយកចិត្តទុកដាក់ទៅលើគោលការណ៍គន្លឹះដែលមានភ្ជាប់មកដូចខាងក្រោម។ បន្ថែមពីនេះ ច្បាប់ស្តីពីការការពារអ្នកបញ្ចេញព័ត៌មានទាក់ទងនឹងផលប្រយោជន៍សាធារណៈនៃសាធារណរដ្ឋកូរ៉េ ដែលត្រូវគេគិតថាជាច្បាប់ដ៏ល្អមួយក្នុងសកលលោក អាចប្រើប្រាស់ជាគំរូនៅក្នុងការធ្វើសេចក្តីព្រាងច្បាប់របស់កម្ពុជាយើងផងដែរ[25] ។

24 Transparency International, International principles for whistleblower legislation: Best practices for laws to protect whistleblowers and support whistleblowing in the public interest, 2013; see also OECD (CleanGovBiz Initiative), Whistleblower protection: encouraging reporting, 2012, available at: http://www.oecd.org/cleangovbiz/toolkit/50042935.pdf; OECD, G20 Action Plan 7: Protection of Whistleblowers – Whistleblower Protection frameworks, Compendium of best practices and guiding principles for legislation, 2011 (available http://www.g20.org/load/781360580)

25 Received from https://track.unodc.org [accessed 15 June 2015] Direct link: https://track.unodc.org/LegalLibrary/LegalResources/Korea,%20Republic%20of/Laws/Act%20on%20the%20Protection%20of%20Public%20Interest%20Whistleblowers.pdf

## អនុសាសន៍[26] :

### ១ ក្របខ័ណ្ឌនិយមន័យ

ការរាយការណ៍ ឬការផ្លុំកញ្ចែៈ ការបញ្ចេញព័ត៌មានពាក់ព័ន្ធទៅនឹងអំពើពុករលួយ អំពើខុសច្បាប់ ការគៃបន្លំ ឬសកម្មភាពដែលបង្កជាគ្រោះថ្នាក់ ដែលកំពុងត្រូវបានប្រព្រឹត្តឡើងនៅក្នុង ឬដោយស្ថាប័នសាធារណៈឬស្ថាប័នឯកជនដោយរួមមានទាំងការប្រព្រឹត្តខុសតាមការមើលឃើញ ឬដែលអាចនឹងកើតមានឡើង ដែលជាប់ពាក់ព័ន្ធទៅនឹង ឬជាការគម្រាមកំហែងដល់ផលប្រយោជន៍សាធារណៈ ដល់បុគ្គលឯកជន ឬនីតិបុគ្គលដែលនឹងត្រូវប៉ះពាល់ដោយសកម្មភាពនោះ។

### ២ គោលការណ៍រួម

បុគ្គល និងការរាយការណ៍ព័ត៌មានដែលត្រូវបានការពារៈ រាល់បុគ្គលគ្រប់រូប រួមមាន និយោជិត និងបុគ្គលិកនៅក្នុងស្ថាប័នសាធារណៈ ឬឯកជនត្រូវការ :

- យន្តការដែលគួរឲ្យទុកចិត្ត និងងាយស្រួលប្រើប្រាស់ដើម្បីរាយការណ៍អំពើខុសច្បាប់
- ការការពារដ៏រឹងមាំ ប្រឆាំងរាល់គ្រប់ទម្រង់នៃការសងសឹក និង
- យន្តការសម្រាប់ការបញ្ចេញព័ត៌មានទាំងឡាយណាដែលលើកកម្ពស់ការកែទម្រង់ច្បាប់ គោលនយោបាយ ឬនីតិវិធីមិនពេញលេញណាមួយ និងទប់ស្កាត់សកម្មភាពខុសច្បាប់នៅពេលអនាគត។

### ៣ វិសាលភាពនៃការអនុវត្ត

និយមន័យនៃការរាយការណ៍ព័ត៌មាន ឬការផ្លុំកញ្ចែ ដែលទូលំទូលាយៈ ការរាយការណ៍ព័ត៌មាន ឬការផ្លុំកញ្ចែ គឺជាការបញ្ចេញ ឬរាយការណ៍នូវអំពើមិនស្របច្បាប់ រួមមានអំពើពុករលួយ បទល្មើសព្រហ្មទណ្ឌ រំលោភលើកាតព្វកិច្ចផ្លូវច្បាប់ ការខុសឆ្គងនៃតុលាការ គ្រោះថ្នាក់ជាក់លាក់ចំពោះសុខុមាលភាពសាធារណៈ សុវត្ថិភាព ឬបរិស្ថាន ការរំលោភអំណាច ការប្រើប្រាស់មូលនិធិ ឬ

26 Taken from: Transparency International, International principles for whistleblower legislation: Best practices for laws to protect whistleblowers and support whistleblowing in the public interest, 2013. The recommendations selected refer to the recommendations with the following numbers in the original text: 1, 2, 3, 4, 5, 6, 7, 11, 12, 13, 14, 18, and 20. Note that some of the recommendations were changed slightly.

ទ្រព្យសម្បត្តិសាធារណៈដោយគ្មានការអនុញ្ញាត ការខ្ជះខ្ជាយ ឬការគ្រប់គ្រងមិនត្រឹមត្រូវក្នុងបរិមាណសន្ធឹកសន្ធាប់ ទំនាស់ផលប្រយោជន៍ និងសកម្មភាពទាំងឡាយណាដែលលាក់បំពួនរាល់ទង្វើទាំងនេះ។

និយមន័យអ្នករាយការណ៍ព័ត៌មានឬអ្នកផ្លុំកញ្ចែ ដែលទូលំទូលាយៈ អ្នករាយការណ៍ព័ត៌មាន និងសាក្សី ឬអ្នកផ្លុំកញ្ចែ សំដៅទៅលើរាល់និយោជិត ឬបុគ្គលិកនៃស្ថាប័នសាធារណៈឬស្ថាប័នឯកជន ដែលផ្តល់ព័ត៌មានពីសកម្មភាពដែលមានចែងនៅក្នុងនិយមន័យការរាយការណ៍ព័ត៌មាន ឬការផ្លុំកញ្ចែខាងលើហើយជាអ្នកដែលប្រឈមមុខនឹងការសងសឹក។ នេះគឺរួមបញ្ចូលទាំងបុគ្គលដែលមិនមែនជានិយោជិត តែមានទំនាក់ទំនងជាមួយនិយោជកដូចជា អ្នកប្រឹក្សា អ្នកម៉ៅការ សិក្ខាកាម/អ្នកហាត់ការ អ្នកស្ម័គ្រចិត្ត បុគ្គលិក អ្នកធ្វើការបណ្តោះអាសន្ន និងអតីតបុគ្គលិក។

លក្ខខណ្ឌទាបបំផុតសម្រាប់ការការពារអ្នករាយការណ៍ព័ត៌មានៈ «ការជឿជាក់ដោយសមហេតុផល អំពីវត្តមាននៃអំពើខុសច្បាប់» ការការពារត្រូវបានផ្តល់ឲ្យសម្រាប់ការរាយការណ៍ដែលធ្វើឡើងដោយមានការជឿជាក់ដ៏សមហេតុផលថាព័ត៌មាននោះពិតនៅក្នុងពេលរាយការណ៍។ ការជឿជាក់ដោយសមហេតុផល មានន័យថាបុគ្គលម្នាក់សង្ស័យដោយសមហេតុផលអំពីអំពើខុសច្បាប់ណាមួយ ផ្អែកលើភស្តុតាងដែលអាចរកបាន នៅពេលដែលព័ត៌មាននោះត្រូវបានរាយការណ៍។ ការការពារត្រូវធ្វើឡើងផងដែរទៅដល់អ្នកដែលរាយការណ៍ព័ត៌មានដោយមិនត្រឹមត្រូវ ដោយសារកំហុសអចេតនា ហើយការការពារនេះត្រូវតែបន្តធ្វើឡើង ខណៈដែលភាពត្រឹមត្រូវនៃការផ្តល់ព័ត៌មាននោះត្រូវបានវាយតម្លៃ។

## ៤ ការការពារ

ការការពារពីការសងសឹកៈ បុគ្គលគ្រប់រូបគួរតែទទួលបានការការពារប្រឆាំងនឹងគ្រប់ទម្រង់នៃការសងសឹក ការខូចខាតប្រយោជន៍ ឬការរើសអើង ដែលជាប់ពាក់ព័ន្ធទៅនឹង ឬជាលទ្ធផលនៃការដែលខ្លួនបានរាយការណ៍ព័ត៌មាន។ នេះរួមមានរាល់ទម្រង់នៃការខូចខាតដូចជាការបណ្តេញចេញ ការព្យួរវិជ្ជាជីវៈ និងទណ្ឌកម្មការងារផ្សេងៗទៀត ការពិន័យដោយផ្ទេរតំណែង ការរុកគួន ការកាត់បន្ថយតួនាទីឬម៉ោងធ្វើការ ការមិនតម្លើងតួនាទី ឬមិនផ្តល់វគ្គបណ្តុះបណ្តាល ការបាត់បង់ឋានៈនិងផលប្រយោជន៍ និងការគម្រាមកំហែងថានឹងមានអំពើដូចដែលបានរៀបរាប់នេះនឹងកើតឡើងទៅលើខ្លួន។

ការរក្សាការសម្ងាត់ៈ អត្តសញ្ញាណរបស់អ្នករាយការណ៍ព័ត៌មានមិនអាចត្រូវបានបង្ហាញដោយគ្មានការយល់ព្រមដោយច្បាស់ៗ ពីសាមីខ្លួននោះទេ។

សិទ្ធិបដិសេធការចូលរួមក្នុងសកម្មភាពខុសច្បាប់ៈ និយោជិត និងបុគ្គលិក មានសិទ្ធិក្នុងការបដិសេធ មិនចូលរួមប្រព្រឹត្តិអំពើពុករលួយ អំពើខុសច្បាប់ និងអំពើគៃបន្លំ។

ការធានាសិទ្ធិៈ វិធាន ឬកិច្ចព្រមព្រៀងជាលក្ខណៈឯកជន ដែលប៉ះពាល់ដល់ការការពារ និងសិទ្ធិរបស់អ្នករាយការណ៍ព័ត៌មាន និងសាក្សីត្រូវទុកជាមោឃៈ។ ជាឧទាហរណ៍ សិទ្ធិរបស់អ្នករាយការណ៍មានឥទ្ធិពលលុបលើសម្បថ«រក្សាភាពស្មោះត្រង់» និងការព្រមព្រៀងរក្សាការសម្ងាត់ ឬ/និងមិនបញ្ចេញព័ត៌មាន របស់និយោជិត។

អាណាមិកភាពៈ ផ្តល់ការការពារដ៏ពេញលេញមួយទៅដល់អ្នករាយការណ៍ព័ត៌មានដែលបានបញ្ចេញព័ត៌មានជាអាណាមិកហើយដែលក្រោយមក អត្តសញ្ញាណរបស់អ្នកផ្តល់ព័ត៌មាននោះត្រូវបានលាតត្រដាង ដោយមិនមានការយល់ព្រមពីសាមីខ្លួន។

ការការពារផ្ទាល់ខ្លួនៈ អ្នករាយការណ៍ព័ត៌មាននិងសាក្សីដែលការរស់នៅ និងសុវត្ថិភាពរបស់ពួកគេប្រឈមនឹងគ្រោះថ្នាក់រួមទាំងសមាជិករបស់ពួកគេផងនោះ ត្រូវទទួលបាននូវវិធានការការពារផ្ទាល់ខ្លួន។

## ៥ នីតិវិធីនៃការរាយការណ៍ព័ត៌មាន

ឧបករណ៍រាយការណ៍ព័ត៌មាន និងសេចក្តីណែនាំៈ គួរបង្កើតយន្តការ និងឧបករណ៍ច្រើនបែបផ្សេងៗគ្នា សម្រាប់ផ្តល់ព័ត៌មានបទល្មើស សម្រាប់និយោជិត និងបុគ្គលិកនៃទីភ្នាក់ងាររដ្ឋាភិបាល និងក្រុមហ៊ុនដែលធ្វើពាណិជ្ជកម្មជាសាធារណៈនានារួមមាន បណ្តាញផ្តល់ប្រឹក្សា បណ្តាញរាយការណ៍បន្ទាន់ ផតថលអនឡាញ ការិយាល័យច្បាប់ និងមន្ត្រីទទួលបន្ទុកដោះស្រាយបណ្តឹង។ ត្រូវបង្កើតយន្តការដើម្បីការពារសុវត្ថិភាព សន្តិសុខ រក្សាការសម្ងាត់ និងអាណាមិកភាពនៃការរាយការណ៍។

## ៦ ការផ្តល់ជំនួយ និងការចូលរួម

យន្តការដោះស្រាយការខូចខាតដែលមានភាពពេញលេញៈ ក្នុងគោលបំណងដោះស្រាយការខូចខាតរបស់អ្នករាយការណ៍ ត្រូវមានយន្តការដោះស្រាយឲ្យបានពេញលេញ ដែលគ្របដណ្តប់រាល់ផលវិបាកដោយផ្ទាល់ ឬដោយប្រយោល និងផលវិបាកនាពេលអនាគតដែលកើតចេញពីការសងសឹក។ នេះរួមមានទាំងការផ្តល់ជំនួយ និងប្រឹក្សាជាបណ្តោះអាសន្ន ការផ្តល់សេវាមេធាវី និងសោហ៊ុយសន្ទានកម្ម ការផ្ទេរទៅកាន់នាយកដ្ឋាន ឬផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មី ការផ្តល់សំណងចំពោះការខាតបង់កិត្តិយសនិងពេលវេលាប្រកបរបរនាពេលអតីត បច្ចុប្បន្ន និងអនាគត និងការផ្តល់សំណងជម្ងឺចិត្ត។ មូលនិធិសម្រាប់ជំនួយផ្លូវច្បាប់ និងការគាំទ្រដល់អ្នករាយការណ៍ដែលមានតម្រូវការហិរញ្ញវត្ថុចាំបាច់គួរត្រូវបានពិចារណា។

សូមចូលទៅកាន់គេហទំព័រ www.ticambodia.org ដើម្បីទាញយកឯកសារសង្ខេបនេះជាអេឡិចត្រូនិច


**អង្គការតម្លាភាពកម្ពុជា**

ទូរសព្ទ: (+៨៥៥) ២៣ ២១ ៤៤ ៣០ / ២៣ ២១ ៤២ ១១

info@ticambodia.org

www.ticambodia.org

www.facebook.com/ticambodia

www.twitter.com/ticambodia



ការបោះពុម្ពរបាយការណ៍នេះអាចធ្វើទៅបានដោយសារការឧបត្ថម្ភគាំទ្រដ៏សប្បុរសពី **នាយកដ្ឋានការបរទេសនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី** (DFAT) និង ប្រទេស**ស៊ុយអែត តាមរយៈទីភ្នាក់ងារស៊ុយអែត ដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍អន្តរជាតិ** (SIDA)។ ទោះយ៉ាងណាក៏ដោយ ខ្លឹមសារនៃរបាយការណ៍នេះ មិនប្រាកដថា ឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ DFAT និង SIDAទេ។


Australian Aid

SWEDEN